ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ធនាគារជាតិ នៃ កម្ពុជា

លេខ ធ៧-០១៧-៣២៦ ប្រ.ក

# ប្រកាស
# ស្តីពី
# ការផ្តល់វិញ្ញាបនបត្រចំពោះគ្រឹះស្ថានឥណទានជនបទ

## ទេសាភិបាលធនាគារជាតិនៃកម្ពុជា

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៥១៥/៤១៧ ចុះថ្ងៃទី១១ ខែឧសភា ឆ្នាំ២០១៥ ស្តីពី ការតែងតាំង ឯកឧត្តម ជា ចាន់តូ ជាអគ្គទេសាភិបាល ធនាគារជាតិនៃកម្ពុជា ជាថ្មី មានឋានៈស្មើទេសរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/២៧ ចុះថ្ងៃទី២៦ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពី ការរៀបចំនិងការប្រព្រឹត្តទៅនៃធនាគារជាតិនៃកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២០៦/០៣៦ ចុះថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០០៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពី វិសោធនកម្មមាត្រា ១៤ និងមាត្រា ៥៧ នៃច្បាប់ស្តីពី ការរៀបចំនិងការប្រព្រឹត្តទៅនៃធនាគារជាតិនៃកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/១១៩៩/១៣ ចុះថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ១៩៩៩ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពី គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ
- យោងប្រកាសលេខ ធ៨-៩៨-៣៨៥ ប្រ.ក ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៨ ស្តីពី រចនាសម្ព័ន្ធរបស់ធនាគារជាតិនៃកម្ពុជា និងមុខងារ-ភារកិច្ចរបស់បណ្តាអង្គភាពក្រោមឱវាទ
- យោងប្រកាសលេខ ធ១-០១០-១៩៤ ប្រ.ក ចុះថ្ងៃទី២៦ ខែវិច្ឆិកា ឆ្នាំ២០១០ ស្តីពី ការកែសម្រួល ប្រការ ៣ ប្រការ ៤ ប្រការ ៥ ប្រការ ១២ និងប្រការ ១៣ នៃប្រកាសស្តីពី រចនាសម្ព័ន្ធរបស់ធនាគារជាតិនៃកម្ពុជា និងមុខងារ-ភារកិច្ចរបស់បណ្តាអង្គភាពក្រោមឱវាទ
- យោងស្មារតីនៃអង្គប្រជុំថ្នាក់ដឹកនាំធនាគារជាតិនៃកម្ពុជា ថ្ងៃទី១៨ ខែតុលា ឆ្នាំ២០១៧

## សម្រេច
## ជំពូកទី ១
## បទប្បញ្ញត្តិទូទៅ

**ប្រការ ១.-**

ប្រកាសនេះ មានគោលបំណងកំណត់លក្ខខណ្ឌនៃការផ្តល់វិញ្ញាបនបត្រចំពោះគ្រឹះស្ថានឥណទានជនបទ ដែលតទៅនេះហៅថា "គ្រឹះស្ថាន"។



ប្រអប់សំបុត្រលេខ ២៥, ឡូតិ៍លេខ ២២-២៤ មហាវិថី ព្រះនរោត្តម រាជធានីភ្នំពេញ, ទូរស័ព្ទ : (៨៥៥-២៣) ៧២២ ៥៦៣, ទូរស័ព្ទ . ទូរសារ : (៨៥៥-២៣) ៤២៦ ១១៧

**ប្រការ ២.-**

ប្រកាសនេះ មានគោលដៅពង្រឹងប្រសិទ្ធភាពនៃការគ្រប់គ្រងនិងការត្រួតពិនិត្យគ្រឹះស្ថាន ដែលផ្តល់ឥណទានខ្នាតតូច។

**ប្រការ ៣.-**

ប្រកាសនេះ មានវិសាលភាពអនុវត្តចំពោះគ្រឹះស្ថានដែលស្ថិតនៅក្រោមអាណាព្យាបាលរបស់ធនាគារជាតិនៃកម្ពុជា។

## ជំពូកទី ២
## លក្ខខណ្ឌនៃការដាក់ពាក្យស្នើសុំវិញ្ញាបនបត្រ

**ប្រការ ៤.-**

បុគ្គលណា ដែលមានបំណងផ្តល់ឥណទានខ្នាតតូច ត្រូវមានការអនុញ្ញាតជាមុន ពីធនាគារជាតិនៃកម្ពុជា។ គ្រឹះស្ថានមិនអាចធ្វើអាជីវកម្មផ្តល់សេវាហិរញ្ញវត្ថុផ្សេងក្រៅពីឥណទានខ្នាតតូចបានឡើយ លើកលែងតែមានការអនុញ្ញាតពីធនាគារជាតិនៃកម្ពុជា។

**ប្រការ ៥.-**

បុគ្គលណា ដែលមានបំណងដាក់ពាក្យស្នើសុំវិញ្ញាបនបត្រធ្វើប្រតិបត្តិការឥណទានជនបទពីធនាគារជាតិនៃកម្ពុជា ត្រូវបំពេញតាមលក្ខខណ្ឌ ដូចខាងក្រោម៖

១. វិញ្ញាបនបត្រចុះបញ្ជីជាក្រុមហ៊ុនមហាជនទទួលខុសត្រូវមានកម្រិតនៅក្រសួងពាណិជ្ជកម្ម
២. លក្ខន្តិកៈរបស់គ្រឹះស្ថាន
៣. រចនាសម្ព័ន្ធចាត់តាំងរបស់គ្រឹះស្ថាន
៤. កិច្ចព្រមព្រៀងចូលហ៊ុនរបស់ភាគទុនិក ការកាន់កាប់ភាគហ៊ុន និងការអនុវត្តសិទ្ធិបោះឆ្នោត
៥. ឯកសារបញ្ជាក់ដើមទុន
៦. ប្រវត្តិរូបសង្ខេបរបស់ភាគទុនិក ក្រុមប្រឹក្សាភិបាល និងគណៈគ្រប់គ្រង
៧. គោលនយោបាយឥណទាន
៨. ផែនការអាជីវកម្មរយៈពេល ០៣ (បី) ឆ្នាំ និង
៩. ឯកសារផ្សេងទៀតដែលតម្រូវដោយធនាគារជាតិនៃកម្ពុជា។

**ប្រការ ៦.-**

គ្រឹះស្ថានត្រូវមានដើមទុនចុះបញ្ជីអប្បបរមា ចំនួន ២០០.០០០.០០០ រៀល (ពីររយលានរៀល) ហើយមុនពេលចាប់ផ្តើមប្រតិបត្តិការ គ្រឹះស្ថានត្រូវបង់ដើមទុនចុះបញ្ជីនេះ ១០០% (មួយរយភាគរយ) នៅក្នុងគណនីដែលបានបើកនៅធនាគារជាតិនៃកម្ពុជា។

គ្រឹះស្ថានត្រូវរក្សាប្រាក់តម្កល់ធានាលើដើមទុនស្មើនឹង ៥% (ប្រាំភាគរយ) នៃដើមទុនដែលបានចុះបញ្ជីនៅក្នុងគណនីដែលបានបើកនៅធនាគារជាតិនៃកម្ពុជា។

**ប្រការ ៧.-**

គ្រឹះស្ថានត្រូវស្នើសុំការអនុញ្ញាតជាមុនពីធនាគារជាតិនៃកម្ពុជា ប្រសិនបើមានករណី ដូចខាងក្រោម៖

១. ការបើកសាខា

២. ការផ្លាស់ប្តូរនាមករណ៍

៣. ការបង្កើន ឬបន្ថយដើមទុនចុះបញ្ជី

៤. ការកែប្រែលក្ខន្តិកៈ

៥. ការផ្លាស់ប្តូរទីតាំងអាជីវកម្ម

៦. ការផ្លាស់ប្តូរអភិបាល ឬគណៈគ្រប់គ្រង

៧. ការរួមបញ្ចូល ការផ្ទេរ ឬការលក់ផ្នែកខ្លះ ឬទាំងស្រុងនៃភាគហ៊ុន ឬ

៨. ការកែប្រែ ការផ្លាស់ប្តូរ និងបញ្ហាផ្សេងទៀតដែលតម្រូវដោយធនាគារជាតិនៃកម្ពុជា។

## ជំពូកទី ៣
## ការផ្តល់វិញ្ញាបនបត្រ

**ប្រការ ៨.-**

ធនាគារជាតិនៃកម្ពុជានឹងជូនដំណឹងជាលាយលក្ខណ៍អក្សរអំពីសេចក្តីសម្រេចផ្តល់ ឬមិនផ្តល់វិញ្ញាបនបត្រ ក្នុងរយៈពេល ០៣ (បី) ខែ ចាប់ពីពេលបានទទួលពាក្យស្នើសុំពេញលេញ។

ក្នុងករណីធនាគារជាតិនៃកម្ពុជាសម្រេចផ្តល់វិញ្ញាបនបត្រ ធនាគារជាតិនៃកម្ពុជានឹងចេញលិខិតយល់ព្រមជាគោលការណ៍ដោយមានលក្ខខណ្ឌ ដែលមានសុពលភាព ០៦ (ប្រាំមួយ) ខែ។ បន្ទាប់ពីបំពេញកាតព្វកិច្ចតាមលក្ខខណ្ឌនៃលិខិតយល់ព្រមជាគោលការណ៍ គ្រឹះស្ថានត្រូវដាក់ពាក្យស្នើសុំវិញ្ញាបនបត្រពីធនាគារជាតិនៃកម្ពុជា។

ក្នុងករណីមិនបានបំពេញកាតព្វកិច្ច ដែលមានចែងនៅក្នុងលិខិតយល់ព្រមជាគោលការណ៍ លិខិតនេះនឹងត្រូវចាត់ទុកជាមោឃៈ។

**ប្រការ ៩.-**

វិញ្ញាបនបត្រមានសុពលភាពរយៈពេល ០៣ (បី) ឆ្នាំ និងអាចស្នើសុំបន្តជាថ្មីទៀតបាន។ គ្រឹះស្ថានត្រូវដាក់ពាក្យស្នើសុំបន្តសុពលភាពវិញ្ញាបនបត្រ ក្នុងរយៈពេលយ៉ាងតិច ០៣ (បី) ខែ មុនវិញ្ញាបនបត្រផុតសុពលភាព។

**ប្រការ ១០.-**

សោហ៊ុយវិញ្ញាបនបត្រប្រចាំឆ្នាំត្រូវបង់មុនថ្ងៃទី១៥ ខែមករា រៀងរាល់ឆ្នាំ ដូចខាងក្រោម៖

- សម្រាប់ទីស្នាក់ការកណ្តាល ៖ ២.០០០.០០០ រៀល (ពីរលានរៀល)
- សម្រាប់មួយសាខា ៖ ១.០០០.០០០ រៀល (មួយលានរៀល)

គ្រឹះស្ថានដែលទទួលវិញ្ញាបនបត្រក្នុងឆ្នាំ ត្រូវបង់សោហ៊ុយវិញ្ញាបនបត្រ ដូចខាងក្រោម៖

- ក្នុងត្រីមាសទី ១ ៖ ត្រូវបង់ពេញមួយឆ្នាំ
- ក្នុងត្រីមាសទី ២ ៖ ត្រូវបង់បីត្រីមាស
- ក្នុងត្រីមាសទី ៣ ៖ ត្រូវបង់ពីរត្រីមាស
- ក្នុងត្រីមាសទី ៤ ៖ ត្រូវបង់មួយត្រីមាស។

**ប្រការ ១១.-**

គ្រឹះស្ថានត្រូវបង់សោហ៊ុយផ្សេងៗ ដូចខាងក្រោម៖

- ការសិក្សាសំណុំឯកសារ ៖ ៥០០.០០០ រៀល (ប្រាំរយពាន់រៀល)
- ការកែប្រែលក្ខន្តិកៈ ៖ ៥០០.០០០ រៀល (ប្រាំរយពាន់រៀល) ក្នុងមួយទំព័រ
- ការប្តូរវិញ្ញាបនបត្រ ៖ ២.០០០.០០០ រៀល (ពីរលានរៀល)
- ការផ្ទេរភាគហ៊ុន ឬការបង្កើនដើមទុន ឬការបន្ថយដើមទុន៖ អប្បបរមា ៤០០.០០០ រៀល (បួនរយពាន់រៀល) ឬ ០,៥% (សូន្យក្បៀសប្រាំភាគរយ) នៃតម្លៃចារឹកភាគហ៊ុនដែលប្រែប្រួល។

**ប្រការ ១២.-**

គ្រឹះស្ថានដែលត្រូវបានធនាគារជាតិនៃកម្ពុជាមិនផ្តល់វិញ្ញាបនបត្រ ឬដកហូតវិញ្ញាបនបត្រ ត្រូវបញ្ឈប់រាល់សកម្មភាពរបស់ខ្លួនទាំងស្រុងក្នុងរយៈពេល ០៦ (ប្រាំមួយ) ខែ បន្ទាប់ពីទទួលបានសេចក្តីជូនដំណឹងពីធនាគារជាតិនៃកម្ពុជា។

## ជំពូកទី ៤
## កាតព្វកិច្ចរាយការណ៍ និងការត្រួតពិនិត្យ

**ប្រការ ១៣.-**

គ្រឹះស្ថានត្រូវអនុវត្តកាតព្វកិច្ចបង្ហាញព័ត៌មាននិងរាយការណ៍ ដូចខាងក្រោម៖

១. បង្ហាញព័ត៌មានស្របតាមស្តង់ដារគណនេយ្យនៃប្រទេសកម្ពុជា និងបទប្បញ្ញត្តិនានារបស់ធនាគារជាតិនៃកម្ពុជា។

២. ត្រូវផ្ញើរបាយការណ៍ត្រីមាស និងតាមការចាំបាច់ មកធនាគារជាតិនៃកម្ពុជា ដូចខាងក្រោម៖

- របាយការណ៍ទ្រព្យសកម្ម និងទ្រព្យអកម្ម
- របាយការណ៍ចំណូល-ចំណាយ
- របាយការណ៍ឥណទានតាមប្រភេទជំនួញ
- របាយការណ៍ឥណទានចំណាត់ថ្នាក់តាមប្រភេទរូបិយប័ណ្ណ
- របាយការណ៍ចំណាត់ថ្នាក់ឥណទាន
- របាយការណ៍ស្តីពីព័ត៌មានបណ្តាញប្រតិបត្តិការ
- របាយការណ៍អត្រាការប្រាក់ និង
- របាយការណ៍ផ្សេងទៀតដែលតម្រូវដោយធនាគារជាតិនៃកម្ពុជា។



ኢ

គ្រឹះស្ថានត្រូវផ្ញើរបាយការណ៍មកធនាគារជាតិនៃកម្ពុជាយ៉ាងយូរបំផុតត្រឹមថ្ងៃទី១៥ នៃខែទី១ នៃត្រីមាសបន្ទាប់។ គ្រឹះស្ថានត្រូវទទួលខុសត្រូវចំពោះភាពត្រឹមត្រូវនៃរបាយការណ៍ទាំងអស់។

គ្រឹះស្ថានត្រូវតែងតាំងក្រុមហ៊ុនសវនកម្ម ដែលមានការទទួលស្គាល់ពីធនាគារជាតិនៃកម្ពុជា ដើម្បីធ្វើសវនកម្មលើរបាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំរបស់ខ្លួន។

ការត្រួតពិនិត្យដល់ទីកន្លែងអាចនឹងត្រូវបានអនុវត្ត ដោយមាន ឬគ្មានការជូនដំណឹងជាមុន។

**ប្រការ ១៤.-**

គ្រឹះស្ថានត្រូវគណនាការប្រាក់ តាមការកំណត់របស់ធនាគារជាតិនៃកម្ពុជា។

គ្រឹះស្ថានត្រូវផ្តល់ព័ត៌មានជាមុនឲ្យបានច្បាស់លាស់ដល់អតិថិជនអំពី អត្រាការប្រាក់ ការគណនាការប្រាក់ កម្រៃពាក់ព័ន្ធ និងលក្ខខណ្ឌផ្សេងៗនៃការផ្តល់ឥណទាន។ ការប្រាក់ត្រូវគណនា ដោយផ្អែកលើមូលដ្ឋាននៃចំនួនទឹកប្រាក់ឥណទានដែលបានផ្តល់ ដកចេញប្រាក់ដើមដែលបានសង។

គ្រឹះស្ថានត្រូវបង្ហាញអត្រាការប្រាក់ប្រចាំគ្រា និងអត្រាការប្រាក់សមមូលប្រចាំឆ្នាំនៅក្នុងកិច្ចសន្យាឥណទាន និងតារាងស្តីពីការសងរំលស់ឥណទាន។

គ្រឹះស្ថានត្រូវផ្តល់ឥណទានប្រកបដោយតម្លាភាព យុត្តិធម៌ សមហេតុផល និងទទួលខុសត្រូវ និងត្រូវធានាថា ការផ្សព្វផ្សាយ ឬការផ្តល់ព័ត៌មានទៅអតិថិជនមានលក្ខណៈយុត្តិធម៌ ច្បាស់លាស់ និងមិនធ្វើឲ្យមានការភាន់ច្រឡំ។

**ប្រការ ១៥.-**

គ្រឹះស្ថានត្រូវរក្សាការសម្ងាត់នូវរាល់ព័ត៌មានរបស់អតិថិជន លើកលែងតែមានបញ្ញត្តិដោយឡែក។

## ជំពូកទី ៥
## រចនាសម្ព័ន្ធភាគហ៊ុន និងអភិបាលកិច្ច

**ប្រការ ១៦.-**

ភាគទុនិកត្រូវផ្តល់ព័ត៌មានមកធនាគារជាតិនៃកម្ពុជាដូចខាងក្រោម៖

១. អត្តសញ្ញាណនៃភាគទុនិក៖
   ក. ក្នុងករណីជានីតិបុគ្គល៖ នាមករណ៍ក្រុមហ៊ុន រូបភាពគតិយុត្ត អាសយដ្ឋាននៃទីស្នាក់ការកណ្តាល លក្ខន្តិកៈ និងរបាយការណ៍សវនកម្មហិរញ្ញវត្ថុ ជាដើម
   ខ. ក្នុងករណីជារូបវន្តបុគ្គល៖ គោត្តនាមនិងនាម ទីកន្លែងនិងថ្ងៃខែឆ្នាំកំណើត សញ្ជាតិ អាសយដ្ឋានបច្ចុប្បន្ន លិខិតថ្កោលទោស និងឯកសារពាក់ព័ន្ធផ្សេងទៀត។
២. ភាគរយនៃភាគហ៊ុនដែលកាន់កាប់ និងភាគរយនៃសិទ្ធិបោះឆ្នោត។ ភាគទុនិកត្រូវបញ្ជាក់ច្បាស់លាស់ពីប្រភពដើមទុន



l

៣. ចំណងទាក់ទងរវាងភាគទុនិកនិងក្រុមហ៊ុនដែលមានសកម្មភាពហិរញ្ញវត្ថុ ដូចជា ធនាគារ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ និងក្រុមហ៊ុនភតិសន្យាហិរញ្ញវត្ថុ និង

៤. ព័ត៌មានផ្សេងទៀត ដែលតម្រូវដោយធនាគារជាតិនៃកម្ពុជា។

**ប្រការ ១៧.-**

បុគ្គលណាក៏មិនអាចជាសមាជិកក្រុមប្រឹក្សាភិបាល ឬនាយក ឬគណៈគ្រប់គ្រងរបស់គ្រឹះស្ថានដោយផ្ទាល់ ឬតាមរយៈអន្តរការីក្នុងទម្រង់ណាក៏ដោយ ឬត្រូវបានផ្តល់សិទ្ធិចុះហត្ថលេខាក្នុងនាមគ្រឹះស្ថាន ប្រសិនបើរូបវន្តបុគ្គលនោះ៖

១. ត្រូវបានផ្តន្ទាទោសពីបទ៖

- ឧក្រិដ្ឋកម្ម
- ចោរកម្ម ឆបោក ឬរំលោភលើការទុកចិត្ត
- លួចដកហូតយកទ្រព្យសាធារណៈក្នុងតួនាទីខ្លួនជាអ្នកគ្រប់គ្រង
- គៃបន្លំមូលនិធិ ឬមូលបត្រ ឬក្ស័យធន
- ធ្វើព្រឹទ្ធិកម្ម
- ការសម្អាតប្រាក់ ឬហិរញ្ញប្បទានភេរវកម្ម ឬ
- ក្លែង និង/ឬ ប្រើលិខិតឯកជន ឬសាធារណៈក្លែងក្លាយ។

២. ត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារពីបទចេញមូលប្បទានបត្រគ្មានសាច់ប្រាក់

៣. ត្រូវបានផ្តន្ទាទោសជាស្ថាពរនៅបរទេសពីបទឧក្រិដ្ឋ ឬមជ្ឈិម ដែលមានចែងនៅក្នុងចំណុច ១ និង ២ នៃប្រការនេះ

៤. ត្រូវបានផ្តន្ទាទោសនៅព្រះរាជាណាចក្រកម្ពុជា ឬនៅបរទេសពីបទក្ស័យធន ឬការជម្រះបំណុលតាមផ្លូវតុលាការ ឬការជម្រះទ្រព្យសម្បត្តិ

៥. ត្រូវរងវិធានការតាមផ្លូវតុលាការ ដោយការតម្លោះយសពីមុខងារសាធារណៈ ឬ

៦. ត្រូវបានទទួលរងទណ្ឌកម្មខាងវិន័យក្នុងការគ្រប់គ្រងគ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុដែលអាជ្ញាប័ណ្ណត្រូវបានដកហូត។

សមាជិកក្រុមប្រឹក្សាភិបាល នាយក និងគណៈគ្រប់គ្រងដែលត្រូវបានតែងតាំង ត្រូវសុំការអនុញ្ញាតជាមុនពីធនាគារជាតិនៃកម្ពុជា និងផ្តល់ព័ត៌មានតាមការតម្រូវ ដូចក្នុងឧបសម្ព័ន្ធនៃប្រកាសនេះ។

## ជំពូកទី ៦
## ការពិន័យ

**ប្រការ ១៨.-**

ធនាគារជាតិនៃកម្ពុជានឹងដាក់ពិន័យអន្តរការណ៍ដូចខាងក្រោម៖

១. ក្នុងការផ្តល់របាយការណ៍ លិខិតឆ្លើយតប និងការផ្តល់ព័ត៌មានផ្សេងៗ គ្រឹះស្ថានត្រូវរងការពិន័យចំពោះការយឺតយ៉ាវនីមួយៗចាប់ពី ១ ថ្ងៃ ទៅ ១៥ ថ្ងៃ ជាទឹកប្រាក់ចំនួន ៥០.០០០ រៀល (ហាសិបពាន់រៀល) ក្នុងមួយថ្ងៃ និងចាប់ពី ១៦ ថ្ងៃ ឡើងទៅ ចំនួន ១០០.០០០ រៀល (មួយរយពាន់រៀល) ក្នុងមួយថ្ងៃ។

២. គ្រឹះស្ថានត្រូវរងការពិន័យចំពោះការយឺតយ៉ាវក្នុងការបង់សោហ៊ុយវិញ្ញាបនបត្រ ចំនួន ១០០.០០០ រៀល (មួយរយពាន់រៀល) ក្នុងមួយថ្ងៃ ក្នុងរយៈពេលរហូតដល់ ៣០ (សាមសិប) ថ្ងៃ។ ក្នុងករណីមិនអាចបង់សោហ៊ុយនេះ គ្រឹះស្ថានត្រូវរងទណ្ឌកម្មធ្ងន់ធ្ងរជាងនេះទៅទៀត រហូតដល់ត្រូវដកហូតវិញ្ញាបនបត្រ។

៣. គ្រឹះស្ថានដែលមិនគោរពតាមអធិបញ្ញា និង/ឬ ល្មើសបទប្បញ្ញត្តិជាធរមាននឹងត្រូវរងពិន័យជាទឹកប្រាក់ចំនួន ៥០០.០០០ រៀល (ប្រាំរយពាន់រៀល) ក្នុងមួយថ្ងៃ គិតចាប់ពីថ្ងៃប្រសិទ្ធភាពដែលកំណត់ដោយធនាគារជាតិនៃកម្ពុជា។

**ប្រការ ១៩.-**

ធនាគារជាតិនៃកម្ពុជា អាចព្យួរ ឬដកហូតវិញ្ញាបនបត្រ ដោយផ្អែកលើមូលហេតុមួយឬច្រើន ដូចខាងក្រោម៖

- គ្រឹះស្ថានមិនបានចាប់ផ្តើមអាជីវកម្មរយៈពេល ០៦ (ប្រាំមួយ) ខែ បន្ទាប់ពីទទួលបានវិញ្ញាបនបត្រ
- គ្រឹះស្ថានបំពានធ្ងន់ធ្ងរលើច្បាប់ ឬបទប្បញ្ញត្តិជាធរមាន
- គ្រឹះស្ថានស្ម័គ្រចិត្តបញ្ឈប់ប្រតិបត្តិការ បន្ទាប់ពីទទួលបានការយល់ព្រមពីធនាគារជាតិនៃកម្ពុជា
- គ្រឹះស្ថានអសាធនភាព ឬក្ស័យធន ឬស្ថិតក្នុងដំណើរការជម្រះបញ្ជី ឬ
- គ្រឹះស្ថានផ្តល់របាយការណ៍ ឬបង្ហាញព័ត៌មានមិនត្រឹមត្រូវដល់ធនាគារជាតិនៃកម្ពុជា ដែលអាចប៉ះពាល់ធ្ងន់ធ្ងរដល់ការវិភាគ និងការវាយតម្លៃស្ថានភាពរបស់គ្រឹះស្ថាន ជាដើម។

## ជំពូកទី ៧
## អន្តរប្បញ្ញត្តិ

**ប្រការ ២០.-**

គ្រឹះស្ថានដែលបានទទួលវិញ្ញាបនបត្រធ្វើប្រតិបត្តិការ ត្រូវបំពេញដើមទុនចុះបញ្ជីអប្បបរមា ស្របតាមការកំណត់ដូចមានចែងក្នុងប្រការ ៦ នៃប្រកាសនេះ ក្នុងរយៈពេលយ៉ាងយូរបំផុតត្រឹម ០៦ (ប្រាំមួយ) ខែ គិតចាប់ពីប្រកាសនេះចូលជាធរមាន។

**ប្រការ ២១.-**

គ្រឹះស្ថានអាចដាក់ពាក្យស្នើសុំអាជ្ញាប័ណ្ណជាគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ លុះត្រាតែគ្រឹះស្ថាន៖

- បានធ្វើប្រតិបត្តិការឥណទានជនបទ យ៉ាងតិចរយៈពេល ០៣ (បី) ឆ្នាំ
- មានដើមទុនបង់ជម្រះអប្បបរមា ស្របតាមប្រកាសដែលពាក់ព័ន្ធនឹងដើមទុនចុះបញ្ជីអប្បបរមារបស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ

- មានប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុង និងអភិបាលកិច្ចល្អ
- មានស្ថានភាពហិរញ្ញវត្ថុរឹងមាំ
- មានប្រាក់ចំណេញប្រតិបត្តិការប្រកបដោយស្ថិរភាពយ៉ាងតិច ០៣ (បី) ឆ្នាំជាប់គ្នា
- មានប្រព័ន្ធព័ត៌មានវិទ្យាគ្រប់គ្រាន់ និងសមស្របទៅតាមសកម្មភាពប្រតិបត្តិការ និង
- បានបំពេញលក្ខខណ្ឌផ្សេងទៀតតាមការកំណត់របស់ធនាគារជាតិនៃកម្ពុជា។

**ប្រការ ២២.-**

គ្រឹះស្ថានណា ដែលមិនគោរពតាមខ្លឹមសារនៃប្រកាសនេះ នឹងត្រូវទទួលរងទណ្ឌកម្មខាងវិន័យដូចមានចែងក្នុងមាត្រា ៥២ នៃច្បាប់ស្តីពី គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ។

## ជំពូកទី ៨
## អវសានប្បញ្ញត្តិ

**ប្រការ ២៣.-**

ប្រកាសលេខ ធ៧-០២-៤៩ ប្រ.ក ចុះថ្ងៃទី២៥ ខែកុម្ភៈ ឆ្នាំ២០០២ ស្តីពី កាតព្វកិច្ចចុះបញ្ជីរបស់ប្រតិបត្តិករមីក្រូហិរញ្ញវត្ថុ និងការសុំអាជ្ញាប័ណ្ណរបស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ និងបទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយពីប្រកាសនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ ២៤.-**

អគ្គលេខាធិការ អគ្គនាយកត្រួតពិនិត្យ អគ្គនាយកបច្ចេកទេស អគ្គបេឡា អគ្គពិនិត្យ ប្រធាននាយកដ្ឋានអង្គភាពក្រោមឱវាទធនាគារជាតិនៃកម្ពុជាដែលមានការពាក់ព័ន្ធ និងគ្រប់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុដែលស្ថិតនៅក្រោមអាណាព្យាបាលរបស់ធនាគារជាតិនៃកម្ពុជា ត្រូវអនុវត្តម៉ឺងម៉ាត់នូវប្រកាសនេះតាមភារកិច្ចរៀងៗខ្លួន។

**ប្រការ ២៥.-**

ប្រកាសនេះមានប្រសិទ្ធភាពអនុវត្តចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។៚

រាជធានីភ្នំពេញ ថ្ងៃទី ២៥ ខែ តុលា ឆ្នាំ២០១៧

**ទេសាភិបាល**

ជា_ចាន់តូ

**កន្លែងទទួល៖**
- ដូចប្រការ ២៤ "ដើម្បីអនុវត្ត"
- ឯកសារ-កាលប្បវត្តិ

**ចម្លងជូន៖**
- គ្រប់សមាជិកក្រុមប្រឹក្សាភិបាល
- ទីស្តីការគណៈរដ្ឋមន្ត្រី
  "ដើម្បីជ្រាបជាព័ត៌មាន"
- នាយកដ្ឋានរដ្ឋបាលនៃទីស្តីការគណៈរដ្ឋមន្ត្រី
  "ដើម្បីចុះផ្សាយក្នុងរាជកិច្ច"

**ឧបសម្ព័ន្ធ**

*ធ្វើនៅ.........ថ្ងៃទី.........ខែ.........ឆ្នាំ.........*

**សូមគោរពជូន**

**ឯកឧត្តម ទេសាភិបាល ធនាគារជាតិនៃកម្ពុជា**

**កម្មវត្ថុ** ៖ សំណើសុំវិញ្ញាបនបត្រជាគ្រឹះស្ថានឥណទានជនបទ។

**យោង** ៖ ប្រកាសលេខ ធ៧-០១៧-៣២៦ ប្រ.ក ចុះថ្ងៃទី២៥ ខែតុលា ឆ្នាំ២០១៧ ស្តីពី ការផ្តល់វិញ្ញាបនបត្រចំពោះគ្រឹះស្ថានឥណទានជនបទ។

តបតាមកម្មវត្ថុ និងយោងខាងលើ ខ្ញុំបាទ/នាងខ្ញុំ សូមគោរពជូន ឯកឧត្តម ទេសាភិបាល មេត្តាជ្រាបថា ក្រុមហ៊ុន......................................................បានចុះបញ្ជីពាណិជ្ជកម្ម កាលពីថ្ងៃទី........................។ ទន្ទឹមនឹងនោះ ក្រុមហ៊ុនមានដើមទុនបង់ជម្រះចំនួន......................................និងបានបំពេញគ្រប់លក្ខខណ្ឌតម្រូវដូចមានចែងក្នុងប្រកាសខាងលើ ក្នុងគោលបំណងផ្តល់សេវាឥណទានខ្នាតតូច។

ខ្ញុំបាទ/នាងខ្ញុំ សូមភ្ជាប់មកជាមួយនូវសំណុំឯកសារ ដូចខាងក្រោម៖

១. វិញ្ញាបនបត្រចុះបញ្ជីជាក្រុមហ៊ុនមហាជនទទួលខុសត្រូវមានកម្រិតនៅក្រសួងពាណិជ្ជកម្ម
២. លក្ខន្តិកៈរបស់គ្រឹះស្ថាន
៣. រចនាសម្ព័ន្ធចាត់តាំងរបស់គ្រឹះស្ថាន
៤. កិច្ចព្រមព្រៀងចូលហ៊ុនរបស់ភាគទុនិក ការកាន់កាប់ភាគហ៊ុន និងការអនុវត្តសិទ្ធិបោះឆ្នោត
៥. ឯកសារបញ្ជាក់ដើមទុន
៦. គោលនយោបាយឥណទាន
៧. ផែនការអាជីវកម្មរយៈពេល ០៣ (បី) ឆ្នាំ
៨. ប្រវត្តិរូបសង្ខេបរបស់ភាគទុនិក ក្រុមប្រឹក្សាភិបាល និងគណៈគ្រប់គ្រង ដោយភ្ជាប់មកជាមួយនូវសញ្ញាបត្រជំនាញ និងបទពិសោធន៍ការងារ ជាដើម
៩. អត្តសញ្ញាណប័ណ្ណ ឬលិខិតឆ្លងដែន និងលិខិតថ្កោលទោសរបស់ភាគទុនិក ក្រុមប្រឹក្សាភិបាល និងគណៈគ្រប់គ្រង និង
១០. លិខិតអនុញ្ញាតធ្វើការងារក្នុងព្រះរាជាណាចក្រកម្ពុជា (Work Permit) របស់ក្រុមប្រឹក្សាភិបាល និងគណៈគ្រប់គ្រង ក្នុងករណីជាជនបរទេស។

ខ្ញុំបាទ/នាងខ្ញុំ សូមធានាថា រាល់ព័ត៌មាននិងឯកសារដែលបានផ្តល់ ពិតជាត្រឹមត្រូវ និងសូមធានាទទួលខុសត្រូវចំពោះមុខច្បាប់ ជាធរមាន។

សេចក្តីដូចបានជម្រាបជូនខាងលើ សូម ឯកឧត្តម ទេសាភិបាល មេត្តាពិនិត្យ និងសម្រេចដោយក្តីអនុគ្រោះ។

សូម ឯកឧត្តម ទេសាភិបាល មេត្តាទទួលនូវការគោរពដ៏ខ្ពង់ខ្ពស់ អំពីខ្ញុំបាទ/នាងខ្ញុំ។

ហត្ថលេខា និងត្រា
(តំណាងក្រុមហ៊ុន)